កន្លែងចែកអាហារក្នុងរដូវក្ដៅនឹងបើកទ្វារនៅថ្ងៃទី១៥ ខែមិថុនា

នាយកដ្ឋានផ្ដល់សេវាកម្មអាហារសាលារបស់ក្រសួងអប់រំឡុងប៊ីចបានចេញសេចក្ដីប្រកាសប្រចាំឆ្នាំស្ដីអំពីកម្មវិធីអាហារក្នុងរដូវក្ដៅ ដោយជាសហការជាមួយនាយកដ្ឋានសួនឧទ្យាននិងការកំសាន្តរបស់ក្រុងឡុងប៊ីច City of Long Beach Department of Parks, Recreation and Marine ។

ពីថ្ងៃច័ន្ទ ទី១៥មិថុនារហូតទៅដល់ថ្ងៃសុក្រ ទី២១សីហា អាហារថ្ងៃត្រង់និងមានចែកឱ្យកុមារអាយុ១ឆ្នាំដល់១៨ឆ្នាំ ពីម៉ោង១១:៣០ទៅដល់១២:៣០ថ្ងៃត្រង់ នៅតាមទីកន្លែងជាង៣០កន្លែងទូទាំងក្រុងឡុងប៊ីច។ ការចែកអាហារនេះគឺដើម្បីជួយគាំទ្រជាបន្តដល់ការបំប៉នអាហារប្រចាំថ្ងៃដល់កុមារនៅក្នុងពេលឈប់សម្រាកពីរៀន។

ទីកន្លែងចែកអាហារក្នុងរដូវក្ដៅនេះនឹងជួយផ្ដល់ដល់សេចក្ដីចាំបាច់របស់សិស្សានុសិស្សនិងក្រុមគ្រួសារ ខណៈដែលកន្លែងចែកចាយអាហាររបស់ក្រសួងអប់រំបិទទ្វារ បន្ទាប់ពីថ្ងៃបញ្ចប់ឆ្នាំសិក្សានៅថ្ងៃទី១២មិថុនានេះ។

សូមែឆករកេមីលកែន្លងែចកចាយអាហារេដាយចូលេទាក្នុងែវបសាយខាងេក្រាមៈ
http://www.longbeach.gov/globalassets/park/media-library/documents/recreation-programs/programs-and-classes/youth-and-teen-programs/u-s-d-a-summer-food-program/2020---summer-food-program-serving-sites

មើនុយមុខម្ហូបអាហារនឹងមានការផ្លាស់ប្ដូរយោងទៅតាមការមាននូវអាហារ។